ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ០១ ខែឧសភា ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីអំពី
## ការបំពេញបេសកកម្មនៅខេត្តព្រះសីហនុរបស់គណៈប្រតិភូជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ

កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ នៅខេត្តព្រះសីហនុ មានគណៈប្រតិភូជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ អមដំណើដោយឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តមប្រតិភូអមនាយករដ្ឋមន្ត្រី **សុខ ចិន្តា សោភា** និងជាអគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តម **ជូ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយករង លោកប្រធាន អនុប្រធាននាយកដ្ឋាន ចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាច្រើនរូបទៀត។



នៅវេលាម៉ោង ១១:១៥ នាទីព្រឹក ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ គណៈប្រតិភូជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញទស្សនកិច្ច និងពិនិត្យរោងចក្រស្រាបៀអង្គររបស់ក្រុមហ៊ុន Cambrew Co.,Ltd ដែលជាគម្រោងវិនិយោគដ៏ធំមួយក្នុងចំណោមគម្រោងវិនិយោគធំៗនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងសួរសុខទុក្ខ ថ្លែងអំណរគុណ និងកោតសរសើរចំពោះរោងចក្រស្រា

បៀអង្គរ ដែលបានអនុវត្តគម្រោងវិនិយោគបានល្អប្រសើរ និងគ្រោងពង្រីកផលិតផលកម្មរបស់ខ្លួន ដែលមានទំហំធំជាងគេនៅតំបន់អាស៊ី ។ លើសពីនេះទៀត ក្រុមហ៊ុន Cambrew ក៏ជាក្រុមហ៊ុនមួយ ដែលបានបង់ពន្ធធំជាងគេ ក្នុងចំណោមក្រុមហ៊ុនផលិតផលស្រាបៀរនៅក្នុងព្រះរាជណាចក្រកម្ពុជា ។ កន្លងមកក្រុមហ៊ុនបានចូលរួមសហការល្អជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គនាយកដ្ឋានពន្ធដារ ក្នុងការអនុវត្តច្បាប់នានា ដូចជាច្បាប់វិនិយោគ ច្បាប់ស្តីពីសារពើពន្ធ ហើយជាពិសេសបានសហការយ៉ាងពេញទំហឹងក្នុងការដាក់មន្ត្រីពន្ធដារចុះប្រចាំការនៅរោងចក្រដើម្បីត្រួតពិនិត្យផលិតផលជាប់អាករពិសេស ។



លោកប្រធានក្រុមហ៊ុន Cambrew Co.,Ltd ក៏បានសំដែងនូវសេចក្តីសប្បាយរីករាយចំពោះដំណើរទស្សនៈកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ដែលបានមកទស្សនៈកិច្ច នៅរោងចក្ររបស់លោក ហើយបានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជា ក្នុងការគាំទ្រនិងលើកទឹកចិត្តចំពោះគម្រោងវិនិយោគរបស់ក្រុមហ៊ុនលោក ។ លោកប្រធានក្រុមហ៊ុនបានបន្ថែមទៀតថា ប្រសិនបើគ្មានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទេ នោះក្រុមហ៊ុនរបស់លោកក៏ពុំមានការរីកចំរើនដូចសព្វថ្ងៃដែរ ។



បន្ទាប់មកនាវេលាម៉ោង ១៥:០០ នាទី រសៀល នៅថ្ងៃដដែល គណៈប្រតិភូជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញទស្សនកិច្ចរោងចក្រថាមពលអគ្គិសនី ដែលប្រើដោយថាមពលធ្យូងថ្មមានកំលាំង ១០០ គីឡូវ៉ាត ស្ថិតនៅក្រុងព្រះសីហនុ។

នាវេលាម៉ោង ១៨:០០ នាទី ល្ងាច នៅថ្ងៃដដែល នៅបន្ទប់ Ballroom ២ ជាន់ផ្ទាល់ដី នៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អមដោយ ឯកឧត្តម **ជូ ទិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គង់ ទិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយប្រធាន អនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រះសីហនុ សាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ សាខាគយនិងរដ្ឋាករកំពង់ផែស្វយ័តក្រុងព្រះសីហនុ សាខាពន្ធដារខេត្តព្រះសីហនុ និងរតនាគារខេត្តព្រះសីហនុ ។




នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ វេលាម៉ោង ០៨:០០ នាទីព្រឹក គណៈប្រតិភូជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញចូលរួមជាអធិបតី ក្រោមអធិបតីភាពរបស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសំណេះសំណាលជាមួយបងប្អូនកម្មករ និងនិយោជិត នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។


